**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែក និង កាមរោគ**

## កំណត់ហេតុ
## កិច្ចប្រជុំបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកញ្ញា ថ្ងៃទីសាមសិប វេលាម៉ោងប្រាំបួនព្រឹកនៅសាលប្រជុំមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ បានរៀបចំកិច្ចប្រជុំបច្ចេកទេសមួយ ដើម្បីរាយការណ៍ពីការអនុវត្តការងារប្រចាំថ្ងៃ លើកឡើងបញ្ហាប្រឈមនានា ព្រមទាំងស្វែងរកដំណោះស្រាយ ក្រោមអធិបតីភាព លោកវេជ្ជបណ្ឌិត **លី ពេញស៊ុន** ប្រធានមជ្ឈមណ្ឌលជាតិ។

សមាសភាពដែលបានអញ្ជើញចូលរួម:

| | | |
|---|---|---|
| ១. លោកវេជ្ជ. | លី ពេញស៊ុន | ប្រធានមជ្ឈមណ្ឌលជាតិ |
| ២. លោកវេជ្ជ. | អ៊ុក វិជ្ជា | អនុប្រធានមជ្ឈមណ្ឌលជាតិ |
| ៣. លោកវេជ្ជ. | សំរិត សុវណ្ណរិទ្ធ | ប្រធានការិយាល័យបច្ចេកទេស |
| ៤. លោកវេជ្ជ. | ង៉ូវ បូរ៉ា | អនុប្រធានការិយាល័យបច្ចេកទេស |
| ៥. លោកវេជ្ជ. | គឹម ប៊ុណ្ណា | អនុប្រធានការិយាល័យបច្ចេកទេស |
| ៦.លោកវេជ្ជ. | កាអឿន ចិត្រា | មន្ត្រីបច្ចេកទេសនៃការិយាល័យបច្ចេកទេស |
| ៧.លោក | Gary Daigle | Management and M&E technical advisor |
| ៨.លោក | តូច វិសាល | ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ |
| ៩. លោកឱសថ. | ម៉ុម ច័ន្ទដារ៉ា | ប្រធានផ្នែកមន្ទីរពិសោធន៍ |
| ១០. លោកវេជ្ជ. | មុន ផល្គុន | ប្រធានផ្នែកអង្កេតតាមដាន |
| ១១. លោកស្រីវេជ្ជ. | សៅ សុគន្ធមាលីនី | អនុប្រធានផ្នែកស្រាវជ្រាវ |
| ១២.លោកស្រីវេជ្ជ. | ចឺ សុផល្លា | អនុប្រធានគ្លីនិកកាមរោគ និងសើស្បែក |
| ១៣.លោកស្រីវេជ្ជ. | ម៉ុក សុគន្ធារី | មន្ត្រីផ្នែកBCC |
| ១៤. លោកគ្រូពេទ្យ | ជា ចំណាន | មន្ត្រីជាន់ខ្ពស់នៃផ្នែកគ្រប់គ្រងទិន្នន័យ |
| ១៥. លោកវេជ្ជ. | ជា ច័ន្ទកុសលមុនី | ប្រធានផ្នែកផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ |
| ១៦. លោកវេជ្ជ. | កយ សុខា | មន្ត្រីផ្នែកផែនការ តាមដាន និងរបាយការណ៍ |
| ១៧. លោក | ហេង សុជាត | មន្ត្រីផ្នែកផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ |
| ១៨. លោកស្រី | យុន ចាន់ផាណេត | ប្រធានគណនេយ្យគម្រោងមូលនិធិសកល |

១៩. លោក លឹម ធានចាយ មន្ត្រីគណនេយ្យគម្រោងមូលនិធិសកល
២០. លោក ឈូក ចន្ថា មន្ត្រីសម្របសម្រួលគម្រោងUD-CDC
២១. លោក ឡេង ច័ន្ទរតនា មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ
២២. លោក ប៊ូ វឌ្ឍនៈ មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ
២៣. លោក កែ អាងហេង មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ
២៤. កញ្ញា ឯក សុខឡេង មន្ត្រីផ្នែកគ្រប់គ្រងឱសថ និងបរិក្ខារ
បញ្ជាក់:ក្នុងកិច្ចប្រជុំនេះមានអវត្តមាន ផ្នែកលទ្ធកម្ម និងផ្នែកSTI។

ជាកិច្ចចាប់ផ្តើមលោកវេជ្ជ. **លី ពេញស៊ីន** ជាប្រធានអង្គប្រជុំបានធ្វើកិច្ចស្វាគមន៍ទៅកាន់ថ្នាក់ដឹកនាំក៏ដូចជាមន្ត្រីរាជការទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ។ បន្ទាប់មកលោកប្រធានក៏បានឲ្យអង្គប្រជុំទាំងមូល កំណត់ពេលវេលាប្រជុំឲ្យបានច្បាស់លាស់ និងទៀងទាត់គឺៈ

១. កិច្ចប្រជុំ ប្រព្រឹត្តិទៅក្នុងរយៈពេលពីរខែម្តង ចាប់ពីពេលនេះតទៅ

២. កិច្ចប្រជុំគឺកំណត់យកថ្ងៃចន្ទ ដើមខែ លើកលែងចំថ្ងៃឈប់សម្រាកត្រូវរម្កិលទៅមុខឬថយក្រោយតាមភាពជាក់ស្តែង។

៣. របៀបវារៈចំនួន២មកពិភាក្សាៈ

ក. រាយការណ៍ពីការអនុវត្តការងារកន្លងមក បញ្ហាប្រឈម និងផែនការបន្តរបស់ផ្នែកនីមួយៗ

ខ. បញ្ហាផ្សេងៗ។

៤. ជ្រើសរើសលោកវេជ្ជ. **ផ្លង់ សុវឌ្ឍនា** និងលោកវេជ្ជ. **កយ សុខា** ជាលេខាកត់ត្រា និងទទួលរបៀបវារៈតាមផ្នែកនីមួយៗ ដើម្បីដាក់ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំលើកក្រោយ។

បន្ទាប់មកលោកប្រធានមជ្ឈមណ្ឌលជាតិ បានអនុញ្ញាតិឲ្យប្រធានឬតំណាងផ្នែកនីមួយៗធ្វើការរាយការណ៍ៈ

**ក.**លោកវេជ្ជ. **មុន ផល្គុន** ប្រធានផ្នែកអង្កេតតាមដាន បានរាយការណ៍គឺៈ

- របាយការណ៍ជាផ្លូវការរបស់ IBBS PWID/PWUD2018 រួចរាល់នៅតែកំពុងរង់ចាំការចុះហត្ថលេខាឯកភាពពីសំណាក់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ លោកស្នើសូមលោកប្រធានមជ្ឈមណ្ឌលជាតិជួយជម្រុញ និងសម្របសម្រួលរឿងនេះផង។
- IBBS MSM/TG 2019 បានបញ្ចប់ការចុះប្រមូលទិន្នន័យ កំពុងរៀបចំនិងបញ្ចប់របាយការណ៍យ៉ាងយូរចុងខែតុលាឆ្នាំ២០១៩នេះ។នឹងគម្រោងរៀបចំសិក្ខាសាលាស្តីពីផ្សព្វផ្សាយលទ្ធផលនេះនាចុងខែតុលា ឆ្នាំ២០១៩ ផងដែរ។
- IBBS EW 2020:
    - នៅពាក់កណ្តាលខែតុលា ឆ្នាំ២០១៩ ពិភាក្សា និងចុះកិច្ចសន្យាជាមួយ Consultant (Mr. Steve Wignall)

- រៀបចំProtocol ស្តីពីIBBS EW 2020
- ស្នើសុំធ្វើលទ្ធកម្ម

ខ.លោកវេជ្ជ. **ង៉ូវ បូរ៉ា** អនុប្រធានការិយាល័យបច្ចេកទេស បានរាយការណ៍គឺ៖

១. ការងារអនុវត្តកន្លងមក:

- B-IACM: អនុវត្តន៍បាន៥១ស្រុកប្រតិបត្តិ(២០ខេត្ត)
- PNTT: បានពន្យាពេល
- Same Day Treatment: SOP បានចេញប្រើប្រាស់រួចរាល់
- QR Code:បានដាក់អនុវត្តន៍ នៅសល់តែ3/68sitesទេ នឹងបញ្ចប់នាពេលឆាប់ៗខាងមុខ។
- 115 System: កំពុងដាក់ដំណើរ និងអនុវត្តន៍ទូទាំងប្រទេស។ ក្នុងឆ្នាំ២០១៩គ្រោងដាក់ដំណើរការ១០ខេត្តទៀតដោយគាំទ្រដោយថវិកាមូលនិធិសកល។ ប៉ុន្តែដោយយឺតយ៉ាវថវិកាគ្រោងនឹងបញ្ចប់ក្នុងត្រីមាសទី៤ឆ្នាំ២០១៩។
- Prep: SOPរួចរាល់ និងបានដាក់ដំណើរការ។

២. ការងារបន្ត:

- ARV Spacing: កំពុងអនុវត្តន៍ និងSiteដែលគ្មានការគាំទ្រពីមូលនិធិសកល គឺកំពុងស្វែងរកដៃគូផ្សេងមកគាំទ្រ។
- BLET: គ្រោងរៀបចំសិក្ខាសាលាផ្សព្វផ្សាយនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩។
- PEP: នឹងដាក់ប្រើប្រាស់Toolថ្មី
- HCV: បានបញ្ចប់ និងឱសថបានផុតកាលកំណត់ប្រើប្រាស់។ ប្រសិនចង់បន្តសកម្មភាពនេះស្នើការសម្រេចពីថ្នាក់ដឹកនាំមជ្ឈមណ្ឌលជាតិ។
  អង្គប្រជុំនឹងធ្វើការសម្រេចនូវក្នុងកិច្ចប្រជុំបន្ទាប់មួយទៀត។

៣. Issue ថ្មី:

- Joint treatment with mental health ដោយប្រើប្រាស់ Tool K10 សម្រាប់ Screen HIV-Mental disease.
- Closed Setting:នៅតែបន្តសកម្មភាពទោះបីការគាំទ្រថវិកាស្តួចស្តើងក៏ដោយ។
- Updat ART Quideline ដោយទទួលការគាំទ្រថវិកាពីCHAI
- ePMTCT
- EID: របាយការណ៍របស់ Angkor Research បង្ហាញថាទិន្នន័យមិនកើនឡើងទេ បើប្រៀបធៀបជាមួយឆ្នាំមុនៗ។ បញ្ហាអង្គប្រជុំក៏បានបង្ហាញពីមូលហេតុខ្លះៗគឺ:
  ១. Dry blood spot:កន្លងមកការបែងចែកដោយLMU និងCMS ទៅឲ្យឃ្លាំងឱសថស្រុកប្រតិបត្តិប៉ុន្តែឃ្លាំងឱសថស្រុកប្រតិបត្តិមិនបានបែងចែកទៅមន្ទីរពិសោធន៍របស់មន្ទីរពេទ្យ

ដោយមិនយល់ពីរបៀបប្រើប្រាស់។ត្រង់ចំណុចនេះ លោកប្រធានមជ្ឈមណ្ឌល បានស្នើឲ្យផ្នែកACU និង Lab unit ពិនិត្យមើលឡើងវិញលើរឿងនេះ។

២. Blood transpotation: ការអនុវត្តកន្លងការបញ្ជូនឈាមមិនចំគោលដៅដែលបែងចែកដោយការគាំទ្រដោយមូលនិធិសកលដែលមានការលំបាកក្នុងការទូទាត់។ ប៉ុន្តែចាប់ពីនេះតទៅ លែងមានបញ្ហាដែលការទូទាត់នឹងធ្វើនៅតាមខេត្តរៀងៗខ្លួនគឺយើងមានខេត្តចំនួន១៩បានអនុម័តកិច្ចព្រមព្រៀងជាមួយមជ្ឈមណ្ឌលជាតិ ខេត្តចំនួន៨បានទម្លាក់ថវិកាចូលគណនីធនាគាររួចរាល់។

៣. ផ្នែកសម្ភពរបស់មន្ទីរពេទ្យខ្លះមិនបញ្ជូនស្ត្រីមានផ្ទៃពោះទៅធ្វើតេស្តEID

៤. បាត់ឬមិនទទួលបានទិន្នន័យរបស់មន្ទីរពិសោធន៍។

៥. ការផ្តល់លទ្ធផលមិនតាមដំណាក់កាល(ការធ្វើតេស្តត្រីមាសមុនមិនទទួលបានលទ្ធផលបែរជាទទួលបានលទ្ធផលត្រីមាសក្រោយវិញ)។ ត្រង់ចំណុចនេះលោកប្រធានផ្នែកមន្ទីរពិសោធន៍ បានសន្យានឹងទៅពិនិត្យការងារនេះឡើងវិញ។

**គ.**លោកឱសថការី **ម៉ុម ច័ន្ទដារ៉ា** ប្រធានផ្នែកមន្ទីរពិសោធន៍ បានរាយការណ៍គឺៈ

- ការងារជាប្រចាំគឺ គាំទ្របច្ចេកទេសក្នុងការពិនិត្យនិងផ្តល់លទ្ធផលទាន់ពេល(Viral Load, CD4, EID...)
- ការងារផ្សេងៗ បានសហការជាមួយការស្រាវជ្រាវផ្សេងៗ
- លោកប្រធានផ្នែកមន្ទីរពិសោធន៍ស្វាគមន៍នូវរាល់មតិកែលម្អ ដើម្បីឲ្យការផ្តល់សេវារបស់ផ្នែកនេះ កាន់តែល្អ។

**ឃ.**លោកស្រីវេជ្ជ. សៅ សុគន្ធមាលីនី អនុប្រធានផ្នែកស្រាវជ្រាវ បានរាយការណ៍គឺៈ

- CQI: ការចុះបំពេញការងារកន្លងមកឃើញថា:

  ១. ការបំពេញឯកសារអ្នកជំងឺរបស់គ្រូពេទ្យភាគច្រើននៅមានការខ្វះចន្លោះ។

  ២. លទ្ធផលតេស្តឈាមរកឃើញដាក់ឈ្មោះគ្រូពេទ្យ មិនត្រូវទៅនឹងកន្លែងផ្តល់សេវា។
- ស្នើឲ្យមានការលើកទឹកចិត្តចំពោះមន្ត្រីបម្រើការនៅក្នុងសេវាទាំងអស់ដែលអនុវត្តន៍ការងារល្អ។ លោកប្រធានមជ្ឈមណ្ឌលបានឯកភាព និងបានស្នើឲ្យផ្នែកស្រាវជ្រាវរៀបចំ លក្ខន្តិកៈក្នុងការ វាយតម្លៃ NCHADSនឹងសម្របសម្រួលចេញនូវលិខិតសរសើរដើម្បីលើកទឹកចិត្ត។

**ង.**លោកវេជ្ជ. សំរិត សុវណ្ណរិទ្ធ ប្រធានការិយាល័យបច្ចេកទេស បានរាយការណ៍គឺៈ

- Dashboard:

  ១. Fix new database

  ២. ដំណាក់កាលបន្ទាប់ថ្នាក់ខេត្តជាអ្នកទទួលខុសត្រូវអនុវត្តន៍ការងារនេះ។
- Computer:

១. កុំព្យូទ័រថ្មី១៩គ្រឿងដែលទិញដោយថវិកាគម្រោងUS-CDC សម្រាប់បែងចែកជំនួសកុំព្យូទ័រចាស់ៗតាមសេវា ART site ទើបបែកចែកនិងមានអ្នកមកទទួលបានតែ៣គ្រឿងប៉ុណ្ណោះ។ ត្រង់ចំណុចនេះលោកវេជ្ជ. សំរិត សុវណ្ណារិទ្ធ បានស្នើឲ្យលោក ប៊ូ វឌ្ឍនៈ ពិនិត្យមើលរឿងនេះឡើងវិញ និងមកឆ្លងថ្នាក់ដឹកនាំ។

២. កុំព្យូទ័រថ្មី៧០គ្រឿងដែលទិញដោយថវិកាគម្រោងមូលនិធិសកលសម្រាប់បំពាក់ជំនួសកុំព្យូទ័រចាស់នៅតាមសេវាVCCT និងគ្លីនិកSTDបានមកដល់ឃ្លាំងNCHADS។ លោកវេជ្ជ. សំរិត សុវណ្ណារិទ្ធ ស្នើឲ្យលោក ប៊ូ វឌ្ឍនៈ រៀបចំតារាងបែងចែកនិងកាលវិភាគមកទទួលតាមខេត្តនីមួយៗដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច និងចេញលិខិតអញ្ជើញមន្ទីរសុខាភិបាលខេត្តចាត់មន្ត្រីទទួលបន្ទុកបញ្ចូលទិន្នន័យVCCT និងSTDមកទទួលកុំព្យូទ័រតាមការបែងចែកនិងកាលវិភាគ។

**ច.លោកវេជ្ជ. ជា ច័ន្ទកុសលមុនី ប្រធានផ្នែកផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍បានរាយការណ៍គឺៈ**

- ការងារស្នូលរបស់ផ្នែកVCCTគឺTraining and Supervision ដើម្បីពង្រឹងការផ្តល់សេវា
- ផ្នែកVCCTទើបតែបញ្ចប់ការចុះវាយតម្លៃតាមសេវាVCCTទទួលលទ្ធផលដូចជា:

  ១. ខ្វះបុគ្គលិកផ្តល់សេវា ដោយសារបុគ្គលិកចាស់បានចូលនិវត្តន៍ និងបុគ្គលិកបានផ្លាស់ទៅបម្រើការងារនៅកន្លែងផ្សេង។

  ២. លោកប្រធានផ្នែកនិងបុគ្គលិកបានចូលរួមជាមួយថ្នាក់ដឹកនាំមន្ទីរសុខាភិបាលខេត្តនិងថ្នាក់ដឹកនាំមន្ទីរពេទ្យបង្អែក ស្នើសុំពួកគាត់ជួយដាក់បុគ្គលិកបំពេញបន្ថែមនៅសេវាVCCT ដើម្បីផ្តល់សេវាពេញលក្ខណៈ និងមានគុណភាព។
- លោកវេជ្ជ. ង៉ូវ បូរ៉ា បានលើកជាយោបល់ថា តើសេវាVCCT និងសេវាART គួរតែដាក់បញ្ចូលគ្នាជាសេវាតែមួយឬយ៉ាងណា? ត្រង់ចំណុចនេះក្រោយការពិភាក្សាបានសម្រេចថាកន្លែងណាអាចដាក់បញ្ចូលគ្នាបានក៏បញ្ចូល។កន្លែងណាដែលមិនដាក់បញ្ចូលបានត្រូវរក្សាដដែលដើម្បីជៀសវាងប៉ះពាល់ដល់ការអនុវត្តការងារកន្លងមក។

**ឆ.លោកវេជ្ជ. គឹម ប៊ុណ្ណា អនុប្រធានការិយាល័យបច្ចេកទេស បានរាយការណ៍គឺៈ**

- គិតមកត្រឹមនេះផ្នែកPMR សហការជាមួយផ្នែកគណនេយ្យគម្រោងមូលនិធិសកល និងសហការជាកម្មវិធីអេដស៍ខេត្តបានរៀបចំផែនការ កិច្ចព្រមព្រៀង(LOA) និងអនុម័តដោយលោកប្រធានមជ្ឈមណ្ឌលជាតិ បាន១៩ខេត្ត។
- ដោយទទួលការស្នើសុំពីខេត្ត លោកប្រធានផ្នែកPMRបានជម្រាបលោកប្រធានមជ្ឈមណ្ឌលនិងស្នើសុំគោលការណ៍សម្រេច គឺកម្មវិធីអេដស៍ខេត្តចង់ស្នើសុំពិសេសដើម្បីទម្លាក់ថវិកា១០០%លើសកម្មភាពបណ្តុះបណ្តាល។ ក្រោយការពិភាក្សានិងឯកភាពពីលោកស្រី យុន ចាន់ផាណេត ប្រធានផ្នែកគណនេយ្យគម្រោង លោកប្រធានយល់ព្រមតាមសំណើ ប៉ុន្តែស្នើ

ឲ្យផ្នែកផែនការ និងផ្នែកគណនេយ្យគម្រោង សហការគ្នាពិនិត្យសំណើរបស់ខេត្តឲ្យបានល្អិតល្អន់ ដើម្បីសម្រេចនិងទម្លាក់ថវិកាឲ្យយកទៅដំណើរការវគ្គបណ្តុះបណ្តាល។

ជ.លោកស្រី យុន ចាន់ផាណេត ប្រធានផ្នែកគណនេយ្យគម្រោង បានរាយការណ៍គឺ៖

- គិតមកត្រឹមនេះ ក្រោយអនុម័តលើផែនការ និងកិច្ចព្រមព្រៀង(LOA)ជាមួយមន្ទីរសុខាភិបាលខេត្តចំនួន១៩ខេត្តមក ផ្នែកគណនេយ្យគម្រោងបានចេញលិខិតជូនដំណឹងស្តីពីការបើកគណនីធនាគារ។ បានទម្លាក់ថវិកាឲ្យខេត្តបានចំនួន៨ខេត្ត និង៣ខេត្តបានដំណើរការសកម្មភាព។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស៖
  ១.មុនបិទរបាយការណ៍ផ្នែកគណនេយ្យស្នើគ្រប់ផ្នែកទាំងអស់ពិនិត្យរាល់សកម្មភាពរបស់ខ្លួន ថាតើត្រូវSaving or Carry forward? ដោយផ្តល់ការពន្យល់មូលហេតុច្បាស់លាស់តាមរយៈការឆ្លើយតប email ដែលផ្នែកគណនេយ្យបានផ្ញើរជូន ដើម្បីឲ្យផ្នែកគណនេយ្យដាក់បញ្ចូលនៅក្នុងការធ្វើរឱ្យនះភាពរបាយការណ៍ហិរញ្ញវត្ថុ និងព្យាករណ៍ថវិកា ទុកសម្រាប់អនុវត្តន៍នៅត្រីមាសបន្ទាប់។
  ២.ពេលវេលាបិទរបាយការណ៍គឺថ្ងៃទី១៥នៃត្រីមាសបន្ទាប់។

ឈ. កំណត់កាលបរិច្ឆេទប្រជុំលើកក្រោយ: **អង្គប្រជុំកំណត់យកថ្ងៃចន្ទ ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩**។

## សង្ខេបសេចក្តីសម្រេចនៃអង្គប្រជុំ៖

១. កំណត់ កិច្ចប្រជុំបច្ចេកទេសប្រព្រឹត្តិទៅក្នុងរយៈពេលពីរខែម្តង និងកំណត់យកថ្ងៃចន្ទ ដើមខែលើកលែងចំថ្ងៃឈប់សម្រាក់ត្រូវរម៉ិលទៅមុខឬថយក្រោយអាស្រ័យលើភាពជាក់ស្តែង។ កំណត់ **ថ្ងៃចន្ទ ទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩** ជាថ្ងៃប្រជុំលើកក្រោយ។

២. ស្នើឲ្យផ្នែកស្រាវជ្រាវរៀបចំលក្ខន្តិកៈក្នុងការ វាយតម្លៃ NCHADSនឹងសម្របសម្រួលចេញនូវលិខិតសរសើរដើម្បីលើកទឹកចិត្តមន្ត្រីបម្រើការនៅក្នុងសេវាទាំងអស់ដែលអនុវត្តន៍ការងារល្អ។

៣.ស្នើឲ្យលោក ប៊ូ វឌ្ឍនៈ ពិនិត្យមើលរឿងកុំព្យូទ័រថ្មី១៨គ្រឿងដែលទិញដោយថវិកាគម្រោងUS-CDCឡើងវិញ និងមកឆ្លងថ្នាក់ដឹកនាំ។ និងរឿងកុំព្យូទ័រថ្មី៧០គ្រឿងដែលទិញដោយថវិកាគម្រោងមូលនិធិសកលសម្រាប់បំពាក់ជំនួសកុំព្យូទ័រចាស់នៅតាមសេវាVCCT និងគ្លីនិកSTD បានមកដល់ឃ្លាំងNCHADSដើម្បីរៀបចំតារាងបែងចែក និងកាលវិភាគមកទទួលតាមខេត្តនីមួយៗដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច និងចេញលិខិតអញ្ជើញមន្ទីរសុខាភិបាលខេត្តចាត់មន្ត្រីទទួលបន្ទុកបញ្ចូលទិន្នន័យVCCT និងSTDមកទទួលកុំព្យូទ័រតាមការបែងចែកនិងកាលវិភាគ។

៤.សេវាVCCT និងសេវាART ដែលចង់ដាក់បញ្ចូលគ្នា ជាសេវាតែមួយគឺថាកន្លែងណាដែលអាចដាក់បញ្ចូលគ្នាបានក៏បញ្ចូលជាសេវាតែមួយ ប៉ុន្តែកន្លែងណាដែលមិនអាចដាក់បញ្ចូលបានត្រូវតែរក្សាដដែលដើម្បីជៀសវាងប៉ះ ពាល់ដល់ការអនុវត្តការងារកន្លងមក។

៥.លោកប្រធានមជ្ឈមណ្ឌល យល់ព្រមលើការស្នើសុំគឺកម្មវិធីអេដស៍ខេត្តចង់ស្នើសុំពិសេសដើម្បីទម្លាក់ថវិកា១០០% លើសកម្មភាពបណ្តុះបណ្តាលក្នុងត្រីមាសទី៤ឆ្នាំ២០១៩ ប៉ុន្តែលោកស្នើឲ្យផ្នែកផែនការ និងផ្នែកគណនេយ្យគម្រោង សហការគ្នាពិនិត្យសំណើរបស់ខេត្តឲ្យបានល្អិតល្អន់ ដើម្បីសម្រេចនិងទម្លាក់ថវិកាឲ្យយកទៅដំណើការវគ្គបណ្តុះបណ្តាល។

កិច្ចប្រជុំបានដំណើរការចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំពីរល្ងាច ថ្ងៃ ខែ ឆ្នាំ ដដែលប្រកបដោយ បរិយាកាសដ៏ស្និតស្នាល រីករាយក្រៃលែង និងទទួលលទ្ធផលគួរឲ្យពេញចិត្ត៕

ថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៩

អ្នកកត់ត្រា

វេជ្ជ. កយ សុខា

បានឃើញ និង ឯកភាព
**ប្រធានអង្គប្រជុំ**

វេជ្ជ.លី_ពេញ ស៊ីន

ចម្លងជូន៖

- អនុប្រធានមជ្ឈមណ្ឌលជាតិ
- ការិយាល័យបច្ចេកទេស
- ការិយាល័យរដ្ឋបាល
- ការិយាល័យគណនេយ្យ
- គ្រប់ផ្នែកទាំងអស់
  «ដើម្បីជ្រាបជាព័ត៌មាន»
- ឯកសារ

| No | Name | Organization | Position | Phone Number | E-mail | Signature |
|---|---|---|---|---|---|---|
| 12 | THEY SOPHALLA | -"- | clinic | 012867647 | they sophalla @ [illegible].com | [signature] |
| 13 | Mok Sokuntheary | -"- | BCC unit | 012 792729 | moksokuntheary@gmail.com | [signature] |
| 14 | Chea Chankosal mony | -"- | Vcct | 012945092 | | [signature] |
| 15 | Lim Theanday | -"- | Finance | 012 935910 | theanday@nchads.org | [signature] |
| 16 | CHHouk Chantha | -"- | PC | 016828686 | chantha@nchads.org | [signature] |
| 17 | Mom Chandara | NCHADS | Lab Manager | 012697228 | mchandara@nchads.org | [signature] |
| 18 | Samreth Sovannarith | NCHADS | Technical Bureau | 0768090086 | sovannarith@nchads.org | [signature] |
| 19 | Ngauv Bora | NCHADS | ACU | 012 900809 | bora@nchads.org | [signature] |
| 20 | Mun Phalkun | -"- | Surveillance | 012 888093 | phalkun@nchads.org | [signature] |
| 21 | Long ChanRatana | -"- | DMU | 012 850799 | chanratana@nchads.org | [signature] |
| 22 | TAOCH.VISAL | -"- | ACCOT. | 011869929 | [illegible]@g.com | [signature] |
| 23 | Kim Bunna | -"- | PMR | 012 880789 | bunna_kim@nchads.org | [signature] |
| 24 | KAY SOKHA | -"- | PMR | 085345222 | kaysokha@nchads.org | [signature] |
| 25 | | | | | | |